# នៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង
# នៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា

## ព័ត៌មានពិស្តារនៃការដាក់ឯកសារ

សំណុំរឿងលេខ : ០០២/១៩-០៩-២០០៧-អវតក/អជសដ
ដាក់ទៅ : អង្គជំនុំជម្រះសាលាដំបូង
ថ្ងៃដាក់ : ថ្ងៃទី១ ខែធ្នូ ឆ្នាំ២០១១
ភាគីអ្នកដាក់ : សហព្រះរាជអាជ្ញា
ភាសាដើម : អង់គ្លេស

ឯកសារបកប្រែ
TRANSLATION/TRADUCTION
ថ្ងៃ ខែ ឆ្នាំ (Date): 01-Dec-2011, 11:52
CMS/CFO: Sann Rada

## ចំណាត់ថ្នាក់ឯកសារ

ប្រភេទឯកសារដែលស្នើឡើងដោយភាគីដាក់ឯកសារ: សាធារណៈ
ចំណាត់ថ្នាក់ឯកសារកំណត់ដោយអង្គជំនុំជម្រះ: សាធារណៈ/Public
ប្រភេទនៃចំណាត់ថ្នាក់ឯកសារ:
ការពិនិត្យចំណាត់ថ្នាក់ឯកសារបណ្តោះអាសន្នឡើងវិញ:
ឈ្មោះមន្ត្រីដែលបានពិនិត្យ:
ហត្ថលេខា:

---

## ចម្លើយតបរួមរបស់សហព្រះរាជអាជ្ញា ទៅនឹង ១) សំណើជាបន្ទាន់របស់ នួន ជា សុំប្តឹងជិតចិត្ត ចៅក្រម CARTWRIGHT និង ២) សំណើរបស់ អៀង សារី សុំឲ្យស៊ើបអង្កេតទៅលើ ការប្រាស្រ័យទាក់ទង *តែម្ខាង* រវាងសហព្រះរាជអាជ្ញាអន្តរជាតិ ចៅក្រម CARTWRIGHT និង អ្នកដទៃ

---

**អ្នកដាក់ឯកសារ:**
សហព្រះរាជអាជ្ញា:
លោកស្រី ជា លាង
លោក Andrew CAYLEY

**អ្នកទទួលឯកសារ:**
អង្គជំនុំជម្រះសាលាដំបូង:
ចៅក្រម និល ណុន, ប្រធាន
ចៅក្រម Silvia CARTWRIGHT
ចៅក្រម យ៉ា សុខន
ចៅក្រមJean-Marc LAVERGNE
ចៅក្រម យូ ឧត្តរា

សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី:

**ចម្លងជូន:**
ជនជាប់ចោទ:

នួន ជា
អៀង សារី
អៀង ធីរិទ្ធ
ខៀវ សំផន

មេធាវីការពារក្តីជនជាប់ចោទ:
លោក សុន អរុណ

ពេជ អង្គ
Elisabeth SIMONNEAU FORT

លោក Michiel PESTMAN
លោក Victor Koppe
លោក អាង ឧត្តម
លោកMichael G.KARNAVAS
លោក ផាត់ ពៅស៊ាង
កញ្ញា Diana ELLIS QC
លោក គង់ សំអុន
លោក Jacques VERGÈS

# I. សេចក្តីផ្តើម និង ប្រវត្តិនីតិវិធី

១- នៅថ្ងៃទី០៤ ខែវិច្ឆិកា ឆ្នាំ២០១១ មេធាវីការពារក្តី នួន ជា បានដាក់លិខិតមួយច្បាប់ជូនចៅក្រម និល ណុន ទាក់ទិននឹង *សំណើសុំព័ត៌មានទាក់ទងនឹងជំនួបសម្ងាត់រវាងលោកស្រីចៅក្រម Cartwright, Andrew Cayley និង/ឬ Knut Rosandhaug*[1]។

២- នៅថ្ងៃទី១៥ ខែវិច្ឆិកា ឆ្នាំ២០១១ មេធាវីការពារក្តី នួន ជា បានដាក់*សំណើសុំព័ត៌មានទាក់ទិននឹងជំនួបសម្ងាត់រវាងលោកស្រីចៅក្រម Silvia Cartwright, សហព្រះរាជអាជ្ញាអន្តរជាតិ និង អនុប្រធានរដ្ឋបាល*[2]។

៣- នៅថ្ងៃទី១៨ ខែវិច្ឆិកា ឆ្នាំ២០១១ មេធាវីការពារក្តី អៀង សារី បានបញ្ជូនតាមរយៈអ៊ីម៉ែលនូវច្បាប់ចម្លងនៃញត្តិស្នើសុំមួយគ្រាន់ជាការគួរសម ដែលមានចំណងជើងថា *សំណើសុំស៊ើបអង្កេតរបស់ អៀង សារី ទាក់ទិននឹងការប្រាស្រ័យទាក់ទងតែម្ខាងរវាង សហព្រះរាជអាជ្ញាអន្តរជាតិ ចៅក្រម Cartwright, និងអ្នកដទៃ*[3]។ នៅថ្ងៃទី១៨ ខែវិច្ឆិកា ឆ្នាំ២០១១ នេះផងដែរ មេធាវីការពារក្តី អៀង សារី បានបញ្ជូនតាមរយៈអ៊ីម៉ែលនូវច្បាប់ចម្លងនៃញត្តិស្នើសុំនេះដែល "បានកែតម្រូវ" គ្រាន់ជាការគួរសម ដោយបានថ្លែងថា "ច្បាប់កែប្រែមានការកែសម្រួលមួយទៅលើកំណត់សំគាល់ចុងទំព័រមួយ"[4]។ តាមព័ត៌មាន និងជំនឿរបស់ខ្លួន អង្គជំនុំជម្រះសាលាដំបូង ("អង្គជំនុំជម្រះ") បានច្រានចោលញត្តិស្នើសុំនេះ ដោយសារតែមិនមានអមមកជាមួយនឹងច្បាប់បកប្រែជាភាសាខ្មែរ[5]។

[1] **E137** *សំណើសុំព័ត៌មានទាក់ទិននឹងជំនួបសម្ងាត់រវាងលោកស្រីចៅក្រម Cartwright, Andrew Cayley និង/ឬ Knut Rosandhaug*, ៤ វិច្ឆិកា ២០១១ ។

[2] **E137/1** *សំណើសុំព័ត៌មានទាក់ទិននឹងជំនួបសម្ងាត់ រវាងលោកស្រីចៅក្រម Silvia Cartwright, សហព្រះរាជអាជ្ញាអន្តរជាតិ និង អនុប្រធានរដ្ឋបាល*, ១៥ វិច្ឆិកា ២០១១ ។ បានជូនដំណឹងនៅថ្ងៃទី១៥ ខែវិច្ឆិកា ឆ្នាំ២០១១ ។

[3] អ៊ីម៉ែល ពី Tanya Rene Pettay, *ច្បាប់ចម្លងគ្រាន់ជាការគួរសមនៃសំណើរបស់ អៀង សារី សុំឱ្យស៊ើបទាក់ទិននឹងប្រាស្រ័យទំនាក់ទំនងតែម្ខាងរវាង សហព្រះរាជអាជ្ញាអន្តរជាតិ ចៅក្រម Cartwright និងអ្នកដទៃ*, ១៨ វិច្ឆិកា ២០១១ ។

[4] អ៊ីម៉ែលពី Michael Karnavas, *ច្បាប់ចម្លងកែតម្រូវដែលបានផ្តល់ជូនគ្រាន់ជាការគួរសមនៃ សំណើរបស់ អៀង សារី សុំឱ្យស៊ើបអង្កេតពាក់ព័ន្ធនឹងការប្រាស្រ័យទាក់ទងសម្រាប់ភាគីតែម្ខាង រវាងសហព្រះរាជអាជ្ញាអន្តជាតិ ចៅក្រម Cartwright និងអ្នកដទៃទៀត*, ១៨ វិច្ឆិកា ២០១១ ។

[5] *ដដែលដូចខាងលើ* ។ ("ដោយសារការបកប្រែមិនអាចបញ្ចប់ឱ្យបានឆាប់រហ័ស អង្គជំនុំជម្រះសាលាដំបូងបានបដិសេធការដាក់ឯកសារនៃសំណើសុំនេះ ថាមិនគ្រប់គ្រាន់...") ។

៤- នៅថ្ងៃទី២២ ខែវិច្ឆិកា ឆ្នាំ២០១១ មេធាវីការពារក្តី នួន ជា បានដាក់ *បណ្តឹងជំទាស់ជាបន្ទាន់ចំពោះចៅក្រម Cartwright* ("ពាក្យសុំ")[6]។ ការដាក់ឯកសារនេះបានភ្ជាប់ និងយោងទៅលើច្បាប់ចម្លងទីមួយដែលបញ្ជូនគ្រាន់ជាការគួរសមរបស់មេធាវីការពារក្តី អៀង សារី ស្នើសុំឱ្យស៊ើបអង្កេតនោះ[7]។ ពាក្យសុំប្តឹងជំទាស់ចៅក្រម Cartwright ឬតាមជម្រើសផ្សេងពីនេះ ដកខ្លួនថយដោយស្ម័គ្រចិត្ត[8]។ ពាក្យសុំនេះមិនស្នើឱ្យស៊ើបអង្កេតទេ ដោយសារវាគ្រាន់តែបានបញ្ចូលចំណែកខ្លះនៃឯកសារភ្ជាប់របស់ អៀង សារី តាមការជ្រើសរើសតែប៉ុណ្ណោះ ដោយមិនបានបញ្ចូលសំណើសុំដំណោះស្រាយរបស់ អៀង សារី ឡើយ[9]។

៥- នៅថ្ងៃទី២៤ ខែវិច្ឆិកា ឆ្នាំ២០១១ មេធាវីការពារក្តី អៀង សារី បានដាក់ញត្តិមួយដែលមានចំណងជើងថា *សំណើរបស់ អៀង សារី សុំឱ្យស៊ើបអង្កេតពាក់ព័ន្ធទៅនឹងការប្រាស្រ័យទាក់ទងជាមួយតែភាគីម្ខាងរវាង សហព្រះរាជអាជ្ញាអន្តរជាតិ ជាមួយ លោកស្រីចៅក្រម Cartwright និងអ្នកដទៃទៀត* ("សំណើ")[10]។ ក្នុងខណៈដែលភាពស្រដៀងគ្នានៃឯកសារពីរដំបូង ដែលបានបញ្ជូនគ្រាន់ជាការគួរសមមានចំណងជើងដូចគ្នានោះ ចំណែកឯកសារដែលបានដាក់ជាចុងក្រោយត្រូវបានគេកែប្រែជាច្រើន[11]។ ឯកសារដែលបានដាក់ បានស្នើឱ្យអង្គជំនុំជម្រះធ្វើការស៊ើបអង្កេតមួយ និង

---

[6] **E137/2** *បណ្តឹងជំទាស់ជាបន្ទាន់ចំពោះចៅក្រម Cartwright,* ២១ វិច្ឆិកា ២០១១ ("ពាក្យសុំ") ។ បានជូនដំណឹងនៅថ្ងៃទី២២ ខែវិច្ឆិកា ឆ្នាំ២០១១ ។

[7] **E137/2.1** *សំណើរបស់ អៀង សារី សុំស៊ើបអង្កេតទាក់ទិននឹង សុំព័ត៌មានទាក់ទិននឹងជំនួបសម្ងាត់ រវាងលោកស្រីចៅក្រម Silvia Cartwright, សហព្រះរាជអាជ្ញាអន្តរជាតិ និងអ្នកដទៃ,* ២២ វិច្ឆិកា ២០១១ "ឯកសារភ្ជាប់របស់ អៀង សារី" ។ ការិយាល័យសហព្រះរាជអាជ្ញាកត់សម្គាល់ឃើញថាសំណើសុំនេះមានចំនួន១០ទំព័របង្ហាញដោយយោងចំពោះផ្នែកខ្លះនៃឯកសារភ្ជាប់របស់ អៀង សារី ព្រមទាំងការដាក់ឯកសារពីរ ពីមុនរបស់ខ្លួន ដែលមានចំនួនទំព័រសរុបប្រហែលចំនួន៩។ ជាលទ្ធផល មេធាវីការពារក្តី នួន ជា ធ្វើឱ្យសេចក្តីណែនាំអនុវត្តត្រង់ចំណុច ៥.១ លែងមានន័យ ត្រង់ថា មានចំនួន១៥ទំព័រកំណត់សម្រាប់ការដាក់ឯកសារបែបនេះ។ វិធាន អវតក វិសោធនកម្មលើកទី៧ ការដាក់ឯកសារនៅចំពោះ អវតក។

[8] **E137/2** ពាក្យសុំ, កំណត់សំគាល់*ខាងដើម*លេខ៦, កថាខណ្ឌទី១ ។

[9] **E137/2** ពាក្យសុំ, កំណត់សំគាល់*ខាងដើម*លេខ៦, កថាខណ្ឌទី២ ។ ពាក្យសុំនេះបញ្ចូលតែកថាខណ្ឌទី៣ ដល់១៦ នៃឯកសារភ្ជាប់របស់ អៀង សារី តែប៉ុណ្ណោះ ។

[10] **E137/3** *សំណើរបស់ អៀង សារី សុំឱ្យស៊ើបអង្កេតពាក់ព័ន្ធទៅនឹងការប្រាស្រ័យទាក់ទងជាមួយតែភាគីម្ខាងរវាង សហព្រះរាជអាជ្ញាអន្តរជាតិ ជាមួយ លោកស្រីចៅក្រម Cartwright និងអ្នកដទៃទៀត,* ២៤ វិច្ឆិកា ឆ្នាំ២០១១ ("សំណើ") ។ បានជូនដំណឹងនៅថ្ងៃទី២៥ ខែវិច្ឆិកា ឆ្នាំ២០១១ ។

[11] មេធាវីការពារក្តី អៀង ធីរិទ្ធ មិនបានផ្តល់ការជូនដំណឹងណាមួយអំពីការកែប្រែទាំងនេះទេ ដែលបានបញ្ចូលនូវការកែប្រែកថាខណ្ឌនានាដែលបញ្ចូលយ៉ាងច្បាស់ទៅក្នុងពាក្យសុំរបស់មេធាវីការពារក្តី នួន ជា ។ សំណើដែលបានដាក់ដោយជោគជ័យនេះ បានបន្ថែម Patricia O'Brien, Knut Rosandhaug "ជាមួយមនុស្សដទៃទៀត" (មិនថាជាប់ទាក់ទង ឬមិនទាក់ទងនឹង អ.វ.ត.ក រួមមាន ប៉ុន្តែមិនកំណត់ត្រឹម

បានផ្តល់យោបល់ជូនអង្គជំនុំជម្រះពីរបៀបដែលការស៊ើបអង្កេតនេះត្រូវបានធ្វើឡើង។ សារណារបស់ អៀង សារី ត្រូវបានគេដាក់នៅក្នុងសំណុំរឿង និងបានជូនដំណឹងដល់សហព្រះរាជអាជ្ញានៅថ្ងៃទី២៥ ខែវិច្ឆិកា ឆ្នាំ២០១១[12]។

៦- នៅក្នុងចម្លើយតបនេះ សហព្រះរាជអាជ្ញាលើកអំពីសេចក្តីសន្និដ្ឋានផ្សេងៗតាមលំដាប់ ដែលសហព្រះរាជអាជ្ញាបានដាក់ និងសន្និដ្ឋានថា អង្គជំនុំជម្រះគួរតែៈ ១) បដិសេធពាក្យសុំនេះដោយសារមិនអាចទទួលយកបាន ឬបើតាមរបៀបផ្សេង ដោយសារមេធាវីការពារក្តី នួន ជា ខកខានមិនបានដាក់បន្ទុករបស់ខ្លួន និង ២) បដិសេធសំណើ ដោយសារមេធាវីការពារក្តី អៀង សារី ខកខានមិនបានដាក់បន្ទុករបស់ខ្លួន។

## II. ពាក្យសុំប្តឹងជំទាស់ចិត្តគួរត្រូវបដិសេធ

៧- នេះជា "ពាក្យសុំបន្ទាន់"ទីពីរ ដែលបានដាក់ដោយមេធាវីការពារក្តី នួន ជា សុំជំទាស់ចិត្តចៅក្រម Cartwright។ ពាក្យសុំទីមួយ ដែលពាក្យសុំនេះក៏ស្នើសុំជំទាស់ចិត្តចៅក្រមអង្គជំនុំជម្រះដទៃទៀតដែរនោះ បានចោទប្រកាន់ថា "ការរកឃើញអង្គហេតុក្នុងសាលក្រម ឌុច... ផ្តល់យ៉ាងពិតប្រាកដ ដល់

ប៉ុណ្ណឹងទេ រួមមិនកំណត់ទាំងអ្នកការទូត និងតំណាងរដ្ឋាភិបាលបរទេស) ដែលបានចូលរួមនៅក្នុងកិច្ចប្រជុំ*សម្រាប់តែម្ខាង* ធ្វើឡើងរវាងលោក Cayley និងចៅក្រម Cartwright" ចំពោះបុគ្គលទាំងឡាយដែលមេធាវីការពារក្តី អៀង សារី ឲ្យយោបល់ថា គួរបានកោះហៅមកចំពោះមុខអង្គជំនុំជម្រះ។ **E137/3**, សំណើ, កំណត់សំគាល់*ខាងដើម*លេខ១០ ត្រង់កថាខ័ណ្ឌទី១ ។ សេចក្តីបន្ថែម និងលុបចេញពីសំណើដើមដែលបានបញ្ជូនពីមុន គឺមានក្នុងឯកសារទាំងមូល រួមទាំង *ឧទាហរណ៍* ការលប់ចេញពីកថាខ័ណ្ឌទី១៤ នូវការទទួលស្គាល់ដែលថាគោលការណ៍ជាមូលដ្ឋានរបស់អង្គការសហប្រជាជាតិឆ្នាំ១៩៨៥ស្តីពីឯករាជ្យភាពនៃអំណាចតុលាការ"មិនមានបទប្បញ្ញត្តិណាមួយដែលហាមឃាត់យ៉ាងច្បាស់អំពីការប្រាស្រ័យទាក់ទង*តែម្ខាង*"ទេ។ ការពិត នៅក្នុងរយៈពេល៦ថ្ងៃ ចន្លោះពេលនៃការព្យាយាមដាក់ឯកសារដំបូងរបស់មេធាវីការពារក្តី អៀង សារី ដំបូង និងលើកទីពីរ ពួកគេហាក់ដូចបានបាត់បង់ខ្លះនូវចំណង់សម្រាប់ការធ្វើអំណះអំណាងរបស់ខ្លួន។ ឧទាហរណ៍ ពួកគេបានយកចេញពាក្យដែលបានគូសបន្ទាត់ពីក្រោមនៅក្នុងប្រយោគខាងក្រោម ពីកថាខ័ណ្ឌទី២៩: "ទង្វើរបស់ចៅក្រម Cartwright ឲ្យឃើញយ៉ាងប្រាកដថា គាត់កំពុងតែចូលរួមពាក់ព័ន្ធយ៉ាងសេរី ក្នុងកិច្ចការផ្សេងៗដែលមិនត្រឹមតែហួសពីអាណត្តិការងាររបស់ខ្លួនជាចៅក្រមមួយរូបនៃអង្គជំនុំជម្រះសាលាដំបូងប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងធ្វើឲ្យមានការប៉ះពាល់ដោយផ្ទាល់ទៅលើភាពត្រឹមត្រូវយុត្តិធម៌ និងការគ្រប់គ្រងរដ្ឋបាលដោយយុត្តិធម៌នៃសំណុំរឿង០០២ ទៀតផង" ។ ពួកគេក៏បានលុបប្រយោគខាងក្រោមនេះពីកថាខណ្ឌទី៣០ និង៣១ ផងដែរ "ចៅក្រមអន្តរជាតិមានសិទ្ធិច្រើនក្នុងការចូលរួមពាក់ព័ន្ធក្នុងការប្រាស្រ័យទាក់ទង*តែម្ខាង* ជាងចៅក្រមជាតិ", "ក្រោមកាលៈទេសៈនៃកិច្ចប្រជុំ *តែម្ខាង* ទាំងនេះដែលគេបានធ្វើឡើង បង្កើតឲ្យមានវប្បធម៌នៃការសង្ស័យយ៉ាងខ្លាំង និងនីទណ្ឌភាពយ៉ាងអាក្រក់" ។

[12] **E137/3** សំណើ, កំណត់សំគាល់*ខាងដើម*លេខ១០ ។

ការបង្ហាញឲ្យឃើញយ៉ាងច្បាស់នៃភាពលំអៀងប្រឆាំងនឹង នួន ជា"[13]។ ពាក្យសុំនោះត្រូវបានបដិសេធ ដោយអង្គជំនុំជម្រះដែលបានថ្លែងថា មេធាវីការពារក្តី នួន ជា បាន "លើកយោងអ្វីដែលគ្មានភ័ស្តុតាងរាំងមាំ"[14]។ ពាក្យសុំនេះគួរត្រូវបានបដិសេធចោលស្រដៀងគ្នាដែរ។

## ក. ពាក្យសុំមិនអាចទទួលយកបាន

៨- ដូចបានទទួលស្គាល់ដោយមេធាវីការពារក្តី នួន ជា[15] វិធាន៣៤ ចែងអំពីលក្ខខណ្ឌតម្រូវផ្សេងៗសម្រាប់ការទទួលយកបណ្តឹងជំទាស់ ជាពិសេស អនុវិធាន ៣, ៤ និង៥ ចែងអំពីលក្ខខណ្ឌតម្រូវចំនួនបួន ដែលជាធាតុផ្សំសម្រាប់ការទទួលយក។ មេធាវីការពារក្តី នួន ជា ក្នុងនាមជាភាគីដាក់ឯកសារ តម្រូវឲ្យ (i) "បញ្ជាក់អំពីទទ្បីករណ៍ឲ្យបានច្បាស់"; (ii) "ផ្តល់ភ័ស្តុតាងគាំទ្រ"; (iii) ដាក់ពាក្យសុំដោយវីរិយភាព (គឺថា "ឲ្យបានឆាប់នៅពេលណាភាគីនោះបានដឹងអំពីទទ្បីករណ៍នោះ") និង (iv) ដាក់ពាក្យសុំពាក់ព័ន្ធនឹងចៅក្រមអង្គជំនុំជម្រះសាលាដំបូង ទៅអង្គជំនុំជម្រះនោះ មុនពេលចេញសាលដីកាស្ថាពរ។ លក្ខខណ្ឌតម្រូវទាំងនេះត្រូវបូកបញ្ចូលគ្នា។

៩- សហព្រះរាជអាជ្ញាពិចារណាថា ពាក្យសុំនេះខកខានមិនបានបំពេញតាមលក្ខខណ្ឌតម្រូវស្តីពីការទទួលយកនេះទេ ដោយហេតុថា ពាក្យសុំនេះមិនបានបង្ហាញ*មូលដ្ឋានភ័ស្តុតាងណាមួយ* ដើម្បីជាការគាំទ្រចំពោះទទ្បីករណ៍សម្រាប់ការប្តឹងជំទាស់ ដូចបានអះអាងដោយមេធាវីការពារក្តី នួន ជា ។ "ភ័ស្តុតាងទាំងអស់ដែលអ្នកដាក់ពាក្យសុំនេះបានពឹងផ្អែក នឹងត្រូវផ្តល់ជូននៅពេលដាក់បណ្តឹងជំទាស់"[16]។ ការគាំទ្រតែមួយគត់ចំពោះពាក្យស្នើសុំនេះដែលចោទអំពី "ការជួបប្រជុំមិនផ្លូវការ *ហួសពី*

---

[13] **E54** *បណ្តឹងជំទាស់ជាបន្ទាន់របស់ នួន ជា ចំពោះចៅក្រមជំនុំជម្រះសាលាដំបូង*, ២៤ វិច្ឆិកា ២០១១, កថាខណ្ឌទី២៦ ("ពាក្យសុំពីមុន") ។ ការពិត គេមានការកត់សំគាល់អំពីការត្រួតគ្នានៃភាសា និងទម្រង់នៃពាក្យសុំទាំងពីរនេះ។ ឧទាហរណ៍ បើធ្វើការប្រៀបធៀបគ្នាឃើញថា កថាខណ្ឌទី២៦ នៃពាក្យសុំពីមុន និងកថាខណ្ឌទី១៥ នៃពាក្យសុំនាពេលនេះ ពាក្យសុំទាំងពីរអះអាងដោយទុកចិត្តខ្លួនឯង: "ចំណុចដ៏សំខាន់នៃពាក្យសុំនេះ គឺសាមញ្ញ..." ។

[14] **E55/4** *សេចក្តីសម្រេចលើបណ្តឹងជំទាស់របស់ អៀង ធីរិទ្ធ, នួន ជា និង អៀង សារី ដែលប្តឹងជំទាស់ ចំពោះលោកចៅក្រម និល ណុន, ជំនុំជម្រះសាលាដំបូង, ចៅក្រម Silvia Cartwright, ចៅក្រម យ៉ា សុខន, ចៅក្រម Jean-Marc Lavergne និង ចៅក្រម ធូ មណី*, ២៣ មីនា ២០១១, កថាខណ្ឌទី១៩ ("សេចក្តីសម្រេចលើពាក្យសុំពីមុន") ។

[15] **E137/2** ពាក្យសុំ, កំណត់សំគាល់*ខាងដើមលេខ*៦, កថាខណ្ឌទី១៣ ។

[16] *សាធារណៈ (ច្បាប់កោសលុប) សេចក្តីសម្រេចលើបណ្តឹងជំទាស់របស់ នួន ជា ប្តឹងជំទាស់ចៅក្រម Marcel Lemonde*, ២៣ មីនា ២០១០, កថាខណ្ឌទី១៨ ។

*អំណាចផ្តល់ឱ្យ* និង*មានតែម្ខាង*'[17] រវាងចៅក្រម Cartwright, លោក Cayley និង/ឬ លោក Rosandhaug គ្មានអ្វីពាក់ព័ន្ធក្រៅតែអំពី "កិច្ចការរដ្ឋបាល និងប្រតិបត្តិការ" ជាសេចក្តីយោងនៅក្នុងកំណត់សំគាល់ចុងទំព័រមួយសំដៅទៅលើ"ព័ត៌មាន" ដែលគេអះអាងថាបានទទួលដោយមេធាវីការពារក្តីពី "ប្រភពដែលគួរឱ្យទុកចិត្តបាន" មួយដែល "បច្ចុប្បន្នសុំមិនបញ្ចេញឈ្មោះ"[18]។ ដោយគ្រាន់តែបានអះអាងពីអត្ថិភាពនៃប្រភពមិនបញ្ចេញឈ្មោះមួយ ដែលខ្លឹមសារ និងសច្ចភាពនៃសេចក្តីថ្លែងរបស់អ្នកនោះ មិនអាចឱ្យអង្គជំនុំជម្រះវាយតម្លៃបានទេ ដោយមិនបានដាក់បន្ទុកត្រឹមកម្រិតអប្បបរមារបស់ភាគីដាក់ឯកសារ ក្នុងការផ្តល់ "ភ័ស្តុតាងគាំទ្រ" អំពីទឡ្ហីករណ៍សម្រាប់ការប្តឹងជំទាស់ដោយកំពុងរបស់អង្គបុរេជំនុំជម្រះ ឈឺចិត្តនោះឡើយ។

១០- សហព្រះរាជអាជ្ញាសង្កេតឃើញថា មេធាវីការពារក្តីហាក់ដូចជាមិនបានបង្ហាញនូវអត្តសញ្ញាណនៃប្រភពអនាមិកដែលអះអាងជូនអង្គជំនុំជម្រះទេ ទោះជាសម្ងាត់បំផុតក៏ដោយ មិនបានផ្តល់ជូនអង្គជំនុំជម្រះនូវកំណត់ហេតុជាលាយលក្ខណ៍អក្សរណាមួយពីប្រភពនោះដែរ សូម្បីតែក្នុងទម្រង់កោសលុបចេញផ្នែកខ្លះ ក៏គ្មានដែរ[19]។ នៅខណៈដែលពាក្យសុំព្យាយាមអង្វរករកសច្ចភាពនៅក្នុងលំហរមួយតាមរយៈការយោងទៅលើអំណះអំណាងខាងអង្គហេតុ[20] និងអង្គច្បាប់[21] ដោយមេធាវីការពារក្តី អៀង សារី, សារណារបស់ខ្លួនឯងផ្ទាល់[22] និងសេចក្តីថ្លែងការណ៍ជាច្រើននៅលើប្រព័ន្ធឃោសនាព័ត៌មានក្តី[23] ការណ៍នេះមិនអាចមានតម្លៃស្មើនឹង "ភ័ស្តុតាងគាំទ្រ" ដែលវិធាន៣៤បានតម្រូវនោះដែរ និងសូម្បីតែពាក្យបណ្តឹងរបស់មេធាវីការពារក្តី នួន ជា ដែលថាចៅក្រម Cartwright មិនឆ្លើយតបទៅនឹងការដាក់ឯកសារមុនៗរបស់ នួន ជា ស្តីពីបញ្ហានេះ មិនបានបំពេញបទដ្ឋាននេះបានដែរ[24]។ បើ

[17] **E137/2** ពាក្យសុំ, កំណត់សំគាល់*ខាងដើម*លេខ៦, កថាខ័ណ្ឌទី១៥ ។

[18] **E137/2** ពាក្យសុំ, ឯកសារដដែលដូចខាងលើ, កថាខ័ណ្ឌទី៥៦ ។

[19] សូមអាន *សាធារណៈ (ច្បាប់កោសលុប) សេចក្តីសម្រេចលើបណ្តឹងជំទាស់ចៅក្រមរបស់ នួន ជា ប្តឹងជំទាស់ចៅក្រម Marcel Lemonde*, ២៣ មីនា ២០១០, កថាខ័ណ្ឌទី១៧-១៩ (រកឃើញភ័ស្តុតាងមិនគ្រប់គ្រាន់ដើម្បីគាំទ្រដល់ការប្តឹងជំទាស់ ដែលមានព័ត៌មានតែមួយគត់ដែលបានដាក់ជូន គឺកំណត់ហេតុធ្វើសម្បថក្រោមឈ្មោះបុគ្គលខ្លួនឯងផ្ទាល់) ។

[20] **E137/2** ពាក្យសុំ, កំណត់សំគាល់*ខាងដើម*លេខ៦, កថាខ័ណ្ឌទី២ ។

[21] **E137/2** ពាក្យសុំ, ឯកសារដដែលដូចខាងលើ, កថាខ័ណ្ឌទី៩ ។

[22] **E137/2** ពាក្យសុំ, ឯកសារដដែលដូចខាងលើ, កថាខ័ណ្ឌទី៦ និង៤៩ ។

[23] **E137/2** ពាក្យសុំ, ឯកសារដដែលដូចខាងលើ, កថាខ័ណ្ឌទី៦ និងកំណត់សំគាល់ទី៤០ និង៦០ ។

[24] **E137/2** ពាក្យសុំ, ឯកសារដដែលដូចខាងលើ, កថាខ័ណ្ឌទី១៧ ។

សិនការណ៍នោះគ្រប់គ្រាន់ ចៅក្រមណាម្នាក់ដែលមិនបានឆ្លើយទៅនឹងការដាក់ឯកសារមិនចាំបាច់ណាមួយការ អាចជាកម្មវត្ថុនឹងបណ្តឹងជិតចិត្ត។

១១- លក្ខខណ្ឌតម្រូវអំពីភាពអាចទទួលយកបាន នៅក្នុងវិធាន៣៤នៃវិធានផ្ទៃក្នុង គឺជាយន្តការសម្រាប់ច្រោះសមស្រប ក្នុងការទប់ស្កាត់ការប្រើប្រាស់ដោយមិនត្រឹមត្រូវនូវពេលវេលារបស់តុលាការ និងធនធានដ៏តិចតួច ដើម្បីស្រាយចំពោះពាក្យបណ្តឹងដែលជាក់ស្តែងគ្មានមូលដ្ឋាន និងមិនមានការចង្អុលបង្ហាញភ័ស្តុតាង។ នេះគឺស្របគ្នាទាំងស្រុងទៅនឹងគំរូដែលបានអនុម័តយក ដោយវិធានស្តីពីនីតិវិធី និងភ័ស្តុតាងរបស់តុលាការឧក្រិដ្ឋកម្មអន្តរជាតិ ព្រមទាំងទៅនឹងបទបញ្ជានានាដែលស្ថិតនៅក្រោមវិធានទាំងនេះ នៅក្នុងការដោះស្រាយលើបណ្តឹងនានាស្តីពីអំពើខុសឆ្គងប្រឆាំងទៅនឹងចៅក្រម ឬរដ្ឋអាជ្ញា។ អត្ថបទច្បាប់ទាំងនេះណែនាំដល់ប្រធានឱ្យដឹកនាំធ្វើការវាយតម្លៃជាបឋមមួយ និងទុកទៅម្ខាងនូវពាក្យបណ្តឹងទាំងឡាយដែល "ជាអនាមិក ឬដែលជាក់ស្តែងគ្មានមូលដ្ឋាន"[25] ដោយមិនចាំបាច់ធ្វើការពិនិត្យពិចារណាបន្ថែមទៀតនោះទេ។ តុលាការសិទ្ធិមនុស្សអឺរ៉ុប គណៈកម្មការសិទ្ធិមនុស្សអន្តរទ្វីបអាមេរិកាំង និងគណៈកម្មាធិការប្រឆាំងនឹងអំពើទារុណកម្ម - ដែលយុត្តាធិការមានលក្ខណៈរសើបចំពោះទំនាក់ទំនងដោយមិនស្មើភាពគ្នានៃអំណាចរវាងអ្នកដាក់ពាក្យបណ្តឹង និងអាជ្ញាធរនានារបស់រដ្ឋ - បញ្ជាក់ថាពាក្យបណ្តឹងណាមួយនឹង "គ្មានមូលដ្ឋានត្រឹមត្រូវជាក់ស្តែង" ឬ "ជាក់ស្តែងគ្មានហេតុផលសមស្រប" ដែល*អាស្រ័យហេតុនេះ គឺមិនអាចឱ្យទទួលយកបានឡើយ* បើសិនជាពាក្យបណ្តឹងនេះខកខានមិនបានបង្ហាញឱ្យឃើញថា យ៉ាងហោចណាស់ ផ្អែកលើមូលដ្ឋាននៃភ័ស្តុតាង*ដែលគ្រាន់តែឃើញមួយភ្លែតក្រឡេកមើលដំបូង* ឬផ្អែកលើមូលដ្ឋាននៃការគិតទុកជាមុនដែរ[26]។ សហព្រះរាជអាជ្ញាសូមជូនសេចក្តីសន្និដ្ឋានថា អង្គជំនុំជម្រះគួរតែអនុវត្តឱ្យបានត្រឹមត្រូវនូវបទដ្ឋានស្រដៀងគ្នានេះ នៅក្នុងការសម្រេចបញ្ចប់លើពាក្យសុំនេះ។

[25] វិធានស្តីពីនីតិវិធី និងភ័ស្តុតាងនៃតុលាការ ICC, វិធាន ២៦(២)។ បទបញ្ជាសម្រាប់តុលាការ របស់តុលាការ ICC, បទបញ្ជា ១២០-១២១។

[26] សម្រាប់តុលាការសិទ្ធិមនុស្សអឺរ៉ុប (ECHR), សូមអាន: ករណីរឿងក្តីរបស់ *Gomes ទល់នឹង ប្រទេសស៊ុយអែត* (សេចក្តីសម្រេចស្តីពីភាពអាចទទួលយកបាន, ពាក្យសុំលេខ 34566/04, ចុះថ្ងៃទី៧ កុម្ភៈ ២០០៦) ត្រង់ទំព័រ១១ (ដែលតម្រូវឱ្យ "មានហេតុផលជាក់ស្តែងដើម្បីឱ្យជឿ" ធ្វើជាលក្ខណ្ឌនៃការចាប់ផ្តើមមួយសម្រាប់ភាពអាចទទួលយកបាន)។ សម្រាប់តុលាការសិទ្ធិមនុស្សអន្តរទ្វីបអាមេរិកាំង (Inter-Am. C.H.R.), សូមអាន: ករណីរឿងក្តីរបស់ *Monsi Lilia Velarde Retamozo ទល់នឹង ប្រទេសប៉េរូ*, សំណុំរឿងលេខ 12.165, របាយការណ៍លេខ 85/03, តុលាការ Inter-Am. C.H.R., OEA/Ser.L/V/II.118 ឯកសារលេខ ៧០ ពិនិត្យឡើងវិញលើកទី២ ត្រង់ 437 (ឆ្នាំ២០០៣) ត្រង់កថាខណ្ឌទី៤៥។ សូមអានផងដែរករណីរឿងក្តីរបស់ *V. ទល់នឹងប្រទេស បូលីវី*, សំណុំរឿងលេខ 270-07, របាយការណ៍លេខ 40/08, Inter-Am. C.H.R., OEA/Ser.L/V/II.130 ឯកសារលេខ 22, ពិនិត្យឡើងវិញលើកទី១ (ឆ្នាំ២០០៨) ត្រង់កថាខណ្ឌទី៧៩។ ករណីរឿក្តីរបស់ *Herrera y Vargas (La Nación) ទល់នឹង* ប្រទេស Costa Rica, សំណុំរឿងលេខ 12,367, ថ្ងៃទី៣ ធ្នូ, តុលាការ IACHR, របាយការណ៍លេខ

១២- ដោយសារមូលហេតុនេះ សហព្រះរាជអាជ្ញាសូមជូនជាយោបល់ថា អង្គជំនុំជម្រះគួរតែបដិសេធលើពាក្យសុំនេះចោល ព្រោះមិនអាចទទួលយកបានទេ អនុលោមតាមវិធាន៣៤(៣)នៃវិធានផ្ទៃក្នុង។

### ខ. សូម្បីតែពាក្យសុំអាចទទួលយកបានក៏ដោយ ក៏មេធាវីការពារក្ដីរបស់ នួន ជា ខកខានមិនបានដាក់បន្ទុកក្នុងការបង្ហាញភស្តុតាងរបស់ខ្លួន

#### *i. ការសោកល្បែងរបស់អ្នកសង្កេតការណ៍សត្យានុម័ត*

១៣- មេធាវីការពារក្ដីរបស់ នួន ជា មិនទទួលដឹងឮចំពោះការលើកឡើងអំពីភាពលំអៀងជាក់ស្ដែងនេះ[27] ប៉ុន្តែលើកឡើងថា លោកស្រីចៅក្រម Cartwrigh គួរតែត្រូវបានប្ដឹងដឹតចិត្ត ដោយសារតែ "ការបង្ហាញឲ្យឃើញមានលក្ខណៈភាពលំអៀង"[28]។ ដើម្បីនឹងប្ដឹងដឹតចិត្តចៅក្រមណាម្នាក់ដែលបង្ហាញថាមានលក្ខណៈលំអៀងនោះ មេធាវីការពារក្ដីរបស់ នួន ជា តោងតែបង្ហាញឲ្យឃើញថា "កាលៈទេសៈទាំងនេះនឹងបណ្ដាលឲ្យអ្នកសង្កេតការណ៍ប្រកបដោយវិចារណញ្ញាណណាម្នាក់ ត្រូវបានគេ

---

128/01, ឆ្នាំ២០០១ ត្រង់កថាខណ្ឌទី៥០។ របាយការណ៍លេខ 4/04, ញត្តិតវ៉ាលេខ 12,324, ករណីរឿងក្ដីរបស់ *Rubén Luis Godoy*, ប្រទេសអាហ្សង់ទីន, ថ្ងៃទី២៤ កុម្ភៈ ឆ្នាំ២០០៤ ត្រង់កថាខណ្ឌទី៤៣ និងរបាយការណ៍លេខ29/07, ញត្តិតវ៉ាលេខ 712-03, ករណីរឿងរបស់ *Elena Tellez Blanco*, ប្រទេសCosta Rica, ថ្ងៃទី២៦ មេសា ២០០៧ ត្រង់កថាខណ្ឌទី៥៨។ សម្រាប់អនុសញ្ញាប្រឆាំងនឹងការធ្វើទារុណកម្ម (CAT) សូមអាន: សេចក្ដីអធិប្បាយផ្ដល់មតិទូទៅលេខ០១: ការអនុវត្តនូវមាត្រា៣ នៃអនុញ្ញាក្នុងបរិបទនៃមាត្រា២២ (ថ្ងៃទី១១/២១/១៩៩៧។ ឯកសារលេខ A/53/44, ឧបសម្ព័ន្ធទី IX, សេចក្ដីអធិប្បាយផ្ដល់មតិទូទៅលេខ០១ លើអនុសញ្ញាប្រឆាំងនឹងការធ្វើទារុណកម្ម(CAT) (សេចក្ដីអធិប្បាយផ្ដល់មតិទូទៅ) ត្រង់កថាខណ្ឌទី៤-៦។ ករណីរឿងក្ដីរបស់ 6 H.I.A. ទល់នឹងប្រទេសស៊ុយអែត, ការប្រាស្រ័យទាក់ទងលេខ 216/2002, U.N. Doc. CAT/C/30/D/216/2002 (ឆ្នាំ២០០៣) (សេចក្ដីសម្រេចរបស់គណៈកម្មាធិការប្រឆាំងនឹងអំពើទារុណកម្ម អនុលោមតាមមាត្រា២២ នៃអនុសញ្ញាស្ដីពីការប្រឆាំងនឹងការធ្វើទារុណកម្ម និងប្រព្រឹត្តិកម្មអមនុស្សធម៌ ឬបន្ទាបបន្ថោក ឬការផ្ដន្ទាទោសចំពោះអំពើសាហាវព្រៃផ្សៃដទៃទៀត -សម័យប្រជុំលើកទី៣០ -ការប្រស្រ័យទាក់ទងលេខ 216/2002 ) ត្រង់កថាខណ្ឌទី ៦.១ - ៦.២។

[27] ឯកសារលេខ **E137/2** ពាក្យសុំ, កំណត់សំគាល់លេខ៦ *ខាងដើម* ត្រង់កថាខណ្ឌទី១៥។ "ត្រូវតែសង្កត់ធ្ងន់ថានៅដើមដំបូងថា មេធាវីការពារក្ដីមិនបានលើកឡើងអំពីអត្ថិភាពនៃភាពលំអៀង*ជាអត្តនោម័ត*ណាមួយ (គឺបានន័យថា, ភាពលំអៀងជាក់ស្ដែង) ពីសំណាក់លោកស្រីចៅក្រម Cartwright នោះឡើយ"។

[28] *ករណីរឿងក្ដីរបស់ រដ្ឋអាជ្ញា ទល់នឹង Furundžija,* សំណុំរឿងលេខ IT-95-17/1-A, សាលក្រម, ចុះថ្ងៃទី២១ កក្កដា ២០០០ , កថាខណ្ឌទី ១៨៩ ("ករណីរឿងក្ដីរបស់ *Furundžija*")។

ផ្តល់ពត៏មានយ៉ាងត្រឹមត្រូវ ដើម្បីឲ្យក្តាប់បានអំពីភាពលំអៀងនេះ"[29] (ការសាកល្បងរបស់អ្នកសង្កេតការណ៍សត្យានុម័ត)។

១៤- ការសាកល្បងរបស់អ្នកសង្កេតការណ៍សត្យានុម័ត គឺខុសគ្នាឆ្ងាយពីបទដ្ឋានដែល *មិនសូវមានសារៈសំខាន់* ដែលបានដាក់ជូនអង្គជំនុំជម្រះ ដោយមេធាវីការពារក្តីរបស់ នួន ជា។ "ការដែលគ្រាន់តែមានអារម្មណ៍ ឬការមន្ទិលសង្ស័យណាមួយដោយជនជាប់ចោទអំពីភាពលំអៀងនោះ គឺមិនគ្រប់គ្រាន់ទេ"[30]។ មេធាវីការពារក្តីរបស់ នួន ជា ត្រូវបង្ហាញក្នុងទម្រង់ជា "ការបង្ហាញភ័ស្តុតាងដែលរឹងមាំ"[31] ថាលោកស្រីចៅក្រមដែលកំពុងមានការប្តឹងតវ៉ា ដែលកំពុងតែប្រើនូវរាល់ជំនាញទាំងអស់របស់គាត់ នឹងមិនអាចមានលទ្ធភាព ដើម្បីដាក់បុរេវិនិច្ឆ័យទៅលើបញ្ហាដែលពាក់ព័ន្ធនឹងសំណុំរឿងបានឡើយ ហើយមិនអាចវិនិច្ឆ័យលើសំណុំរឿងដែលស្ថិតនៅចំពោះមុខលោកស្រីចៅក្រមនោះបានដោយត្រឹមត្រូវបានឡើយ។ ការសាកល្បងនេះបានដាក់ការរារាំងដ៏ខ្ពស់មួយ ពីព្រោះ " នៅពេលដែលភាពលំអៀងពិតប្រាកដ ឬការឲ្យឃើញជារូបភាពពីសំណាក់ចៅក្រមណាម្នាក់នោះ គឺជាការធ្វើឲ្យខូចដល់ជំនឿទុកចិត្តនៅក្នុងការគ្រប់គ្រងកិច្ចការ ុយុត្តិធម៌ ដែលហេតុដូចនេះនឹងបណ្តាលឲ្យមានការប្តឹងជំទាស់ចិត្តចំពោះចៅក្រម ដោយផ្អែកលើមូលដ្ឋាននៃការចោទប្រកាន់នានា អំពីភាពលំអៀងដែលគ្មានមូលដ្ឋាននេះ"[32]។

[29] ឯកសារ **E55/4**, សេចក្តីសម្រេចលើពាក្យសុំពីមុន, កំណត់សំគាល់លេខ១៤ *ខាងដើម* ត្រង់កថាខណ្ឌទី១១។ សូមអានផងដែរ ឯកសារលេខ **E137/2** ពាក្យសុំ, កំណត់សំគាល់លេខ៦ *ខាងដើម* ត្រង់កថាខណ្ឌទី១៥។ ការសាកល្បងត្រូវបានពន្យល់ថាជាចម្លើយតបទៅនឹងសំនួរ, នឹងជា "ជនដែលប្រកបដោយវិចារណញ្ញាណ, ដោយសត្យានុម័ត និងដែលត្រូវបានគេផ្តល់ព័ត៌មាន ... ស្តីពីអង្គហេតុជាក់ស្តែងដែលត្រឹមត្រូវដែលធ្វើឲ្យយល់បានដោយសមហេតុផលថា [លោកស្រីចៅក្រម Cartwright] មិនបាន ឬនឹងមិននាំយកនូវគំនិតដែលប្រកបដោភាពលំអៀងដើម្បីយកមកធ្វើការកាត់សេចក្តីទៅលើសំណុំរឿងនោះទេ, ដែលនោះគឺជាគំនិតមួយដែលបើកទូលាយសម្រាប់ការបញ្ចុះបញ្ចូលឲ្យជឿតាមតាមរយៈភ័ស្តុតាង និងសារណានានារបស់មេធាវីការពារក្តី"។ ករណីរឿក្តីរបស់ *Furundžija*, កំណត់សំគាល់លេខ២៨ *ខាងដើម* ត្រង់កថាខណ្ឌទី១៨៦ ដែលដកស្រង់សំដីរបស់ *ប្រធានាធិបតីនៃសាធារណរដ្ឋអាហ្វ្រិកខាងត្បូង និងជនដទៃទៀត ប្រឆាំងនឹង សហព័ន្ធកីឡារុយប៊ីបាល់ទាត់ និងកីឡាដទៃទៀតនៃអាហ្វ្រិកខាងត្បូង*, សាលក្រមលើពាក្យសុំដកខ្លួន, សំណុំរឿងលេខ 1999 (7) BCLR 725 (CC), ចុះថ្ងៃទី៣ មិថុនា ១៩៩៩។

[30] *ករណីរឿងក្តីរបស់ រដ្ឋអាជ្ញា ទល់នឹង* Karemera et al., សំណុំរឿងលេខ ICTR-98-44-T, *សេចក្តីសម្រេចលើញត្តិរបស់* Joseph *Nzirorera ដែលស្នើសុំប្តឹងជំទាស់ចិត្តចៅក្រម* Byron *និងសុំឲ្យផ្អាកកដំណើរការនីតិវិធី*, ចុះថ្ងៃទី២០ កុម្ភៈ ២០០៩, កថាខណ្ឌទី៥ ("ញត្តិស្នើសុំរបស់ *Nzirorera*")។

[31] ករណីរឿងក្តីរបស់ *Furundžija,* កំណត់សំគាល់លេខ២៨ *ខាងដើម* ត្រង់កថាខណ្ឌទី១៩៧។

[32] ញត្តិស្នើសុំរបស់ *Nzirorera,* កំណត់សំគាល់លេខ៣០ *ខាងដើម* ត្រង់កថាខណ្ឌទី៦។

១៥- "អ្នកសង្កេតការណ៍ប្រកបដោយវិចារណញ្ញាណ" គឺជា"ជនណាម្នាក់ដែលត្រូវបានគេផ្ដល់ព័ត៌មានឲ្យបានដឹងគ្រប់កាលៈទេសៈទាំងអស់ដែលពាក់ព័ន្ធ ដែលរួមមាន អំពីទម្លាប់ប្រពៃណីនៃសុច្ចរិតភាព និងភាពមិនលំអៀងដែលបង្កើតបានជាផ្នែកមួយនៃប្រវត្តិដើម និងបានធ្វើការវាយតម្លៃផងដែរអំពីប្រការដែលថា ភាពមិនលំអៀងគឺជាភារកិច្ចមួយក្នុងចំណោមភារកិច្ចទាំងឡាយរបស់ចៅក្រមដែលបានស្បថថានឹងគោរពប្រតិបត្តិតាម"[33]។ អង្គជំនុំជម្រះបានពន្យល់ថា "ចំណុចចាប់ផ្ដើមសម្រាប់ការសម្រេចណាមួយទៅលើការចោទប្រកាន់អំពីភាពលំអៀង គឺជាការសន្មតទៅលើភាពមិនលំអៀងដែលជាប់ជាមួយនឹងចៅក្រមទាំងឡាយរបស់ អវតក ដោយផ្អែកលើមូលដ្ឋាននៃការធ្វើសម្បថរបស់ពួកគាត់ ដើម្បីចូលកាន់តំណែង នឹងលើគុណវិឌ្ឍិដើម្បីតែងតាំងពួកគេ"[34]។ ហេតុដូចនេះ មេធាវីរបស់ នួន ជា មិនគ្រាន់តែត្រូវលើកនូវភ័ស្តុតាងឲ្យបានគ្រប់គ្រាន់ ដើម្បីដាក់បន្ទុកដែលត្រូវបង្ហាញភ័ស្តុតាងដែលជាធម្មតាអាចអនុវត្តបានចំពោះភាគីដែលដាក់ពាក្យសុំប៉ុណ្ណោះទេ តែត្រូវផ្ដល់ភ័ស្តុតាងឲ្យបានគ្រប់គ្រាន់ផងដែរ ដើម្បី"គេចពីការសន្មតជាមុនដែលតម្រូវនូវលក្ខខណ្ឌដ៏ខ្ពស់មួយ"[35]។

១៦- ការសន្មតអំពីភាពលំអៀងដែលត្រូវតែយកមកប្រើ ដោយអ្នកសង្កេតការណ៍ឯករាជ្យបន្ថែមពីលើការបង្កើតរបាំងបន្ថែមមួយសម្រាប់ឲ្យភាគីណាមួយដែលប្ដឹងជំទាស់ត្រូវពុះពារឆ្លងកាត់ឲ្យបាន ក៏តម្រូវផងដែរឲ្យអ្នកសង្កេតការណ៍ឯករាជ្យធ្វើការសន្មតថា ទោះបីជាស្ថិតនៅក្នុងស្ថានភាពដែលភាគីណាមួយអាចបង្ហាញឲ្យឃើញអំពីបុរេវិនិច្ឆ័យមួយចំនួន ដោយចៅក្រមលើបញ្ហាដែលទាក់ទងនឹងករណីរឿងក្ដីក៏ដោយ ក៏"ចៅក្រមនានានៅតុលាការអន្តរជាតិ "អាចមិនប្រឆាំងនឹងចិត្តនៃជឿ ឬបុរេវិនិច្ឆ័យផ្ទាល់ខ្លួនដែលមិនពាក់ព័ន្ធ"[36]។ លោកស្រីចៅក្រម Cartwright គឺជាអ្នកច្បាប់ដែលមាន

---

[33] ឯកសារលេខ **E55/4**, *សេចក្ដីសម្រេចលើពាក្យសុំពីមុន*, កំណត់សំគាល់លេខ១៤*ខាងដើម* ត្រង់កថាខណ្ឌទី១២ ដែលដកស្រង់សំដីរបស់ *Furundžija*, កំណត់សំគាល់លេខ២៦ *ខាងដើម* ត្រង់កថាខណ្ឌទី១៩០។

[34] ឯកសារលេខ **E55/4**, *សេចក្ដីសម្រេចលើពាក្យសុំពីមុន*, កំណត់សំគាល់លេខ១៤*ខាងដើម* ត្រង់កថាខណ្ឌទី១២ ។

[35] ឯកសារលេខ **E55/4**, *សេចក្ដីសម្រេចលើពាក្យសុំពីមុន*, កំណត់សំគាល់លេខ១៤*ខាងដើម* ត្រង់កថាខណ្ឌទី១២ ។

[36] ករណីរឿងក្ដីរបស់*Furundžija*, កំណត់សំគាល់លេខ២៨ *ខាងដើម* ត្រង់កថាខណ្ឌទី១៩៧ ។ គោលការណ៍ស្ដីពីការគោរពតាមដោយត្រឹមត្រូវចំពោះលទ្ធភាពរបស់ចៅក្រមក្នុងការទុកដោយឡែកនូវការពិចារណារបស់ខ្លួនផ្ទាល់នៅក្នុងការវិនិច្ឆ័យលើករណីរឿងដោយឡែកណាមួយ គឺជាការបង្ហាញភស្តុតាងយ៉ាងច្បាស់។ ឧទាហរណ៍ដូចជា អង្គជំនុំជម្រះសាលាឧទ្ធរណ៍នៃតុលាការ ICTY បានសម្រេចថា ទោះបីជានៅក្នុងករណីណាមួយដែលអាចមាន "ការបង្ហាញភ័ស្តុតាង"ថា ចៅក្រមណាម្នាក់ដែលកំពុងជំនុំជម្រះក្ដីលើករណីមួយ " បានចែករំលែកគោលដៅ និងទិសដៅ"របស់អង្គការមួយដែលតស៊ូមតិប្រឆាំងនឹងឧក្រិដ្ឋកម្មមួយចំនួនដែលត្រូវបានចោទប្រកាន់ថាបានប្រព្រឹត្ត ដោយជនជាប់ចោទនៅក្នុងករណីរឿង ចៅក្រមនឹងអាចមានលទ្ធភាពទុកដោយឡែកនូវទំនោរដែលទោទន់ទៅរក នៅក្នុងករណីដោយឡែកនោះបាននៅមុនពេលធ្វើការសម្រេចដោយលំអៀងទៅលើករណីនោះ។ *ដូចគ្នានឹងខាងលើ* ត្រង់កថាខណ្ឌទី២០០។

គុណវុឌ្ឍិ និងបទពិសោធន៍ខ្ពស់មួយរូប” ហេតុដូចនេះ អ្នកសង្កេតការណ៍ដែលប្រកបដោយវិចារណញ្ញាណបានធ្វើការវាយតម្លៃលើកាលៈទេសៈដែលពាក់ព័ន្ធទាំងអស់រួចហើយ មិនអាចធ្វើការ“សន្និតដោយសេរីៗ”ថា លោកស្រីជាប់ពាក់ព័ន្ធនៅក្នុងការប្រព្រឹត្តិមិនគប្បីដែលរំលោភទៅលើក្រមសីលធម៌តុលាការ និងការរំលោភកាតព្វកិច្ចខាងវិជ្ជាជីវៈរបស់លោកស្រីឡើយ[37]។

១៧- ពិសេសជាងនេះទៀត អ្នកសង្កេតការណ៍ប្រកបដោយសុភវិនិច្ឆ័យគឺស៊ាំនឹងរចនាសម្ព័ន្ធ និងប្រតិបត្តិការរបស់តុលាការអន្តរជាតិ និងលក្ខខណ្ឌតម្រូវនៃកាលៈទេសៈពិសេសទាំងអស់ ដែលចៅក្រមត្រូវបំពេញ។ ជាក់ស្តែងក្នុងកាលៈទេសៈមួយដែល “តុលាការព្រហ្មទណ្ឌអន្តរជាតិណាមួយបានអនុវត្តយុត្តាធិការដែលអាចនាំឱ្យមានការជំនុំជម្រះជាច្រើនលើបណ្តុំនៃអង្គហេតុរួមមួយ... អ្នកសង្កេតការណ៍ប្រកបដោយសុភវិនិច្ឆ័យជឿថាចៅក្រមនៃតុលាការនោះ នឹងត្រូវបានស្នើសុំឱ្យផ្តល់សំអាងហេតុ នៅក្នុងសំណុំរឿងមួយដែលពាក់ព័ន្ធនឹងប្រវត្តិ និងបរិបទនៃសំណុំរឿងមួយផ្សេងទៀត ដែលហេតុផលនេះ មិនធ្វើឱ្យភាគីយល់ថាតុលាការមានភាពលម្អៀង”[38]។ ស្រដៀងគ្នានេះ ដូចដែលពន្យល់បន្ថែមខាងក្រោម អ្នកសង្កេតការណ៍ប្រកបដោយសុភវិនិច្ឆ័យនឹងដឹងថា ចៅក្រមនៃតុលាការអន្តរជាតិ និងចៅក្រមនៃតុលាការដែលប្រើប្រាស់ប្រព័ន្ធច្បាប់ស៊ីវិល ក៏មានតួនាទីបំពេញកិច្ចការរដ្ឋបាលផងដែរដែលតម្រូវឱ្យពួកគាត់ត្រូវប្រាស្រ័យទាក់ទងជាមួយសមាជិកនៃភាគីអយ្យការ និងពុំប៉ះពាល់ដល់ភាពមិនលម្អៀងរបស់ចៅក្រមឡើយ។

១៨- អង្គជំនុំជម្រះឧទ្ធរណ៍នៃតុលាការ ICTY បានព្រមានអំពីគ្រោះថ្នាក់នៃការងាយទទួលយកបណ្តឹងជំទាស់ចៅក្រមដែលពុំស័ក្តិសមនឹងទទួលយក៖

> *ថ្វីបើជាការចំបាច់ដែលថា យុត្តិធម៌ត្រូវមាន ជាការសំខាន់ស្មើគ្នាដែលមន្ត្រីយុត្តិធម៌ត្រូវអនុវត្តភារកិច្ចរបស់ខ្លួនទាំងអង្គុយ និងឈរ ដោយពុំធ្វើឱ្យភាគីជឿតាមរយៈការឆាប់ទទួលស្គាល់នូវការលើកឡើងអំពីភាព*

[37] *ឯកសារលេខ* E55/4 *សេចក្តីសម្រេចលើពាក្យសុំពីមុន*, កំណត់សំគាល់លេខ១៤ ខាងដើម ត្រង់កថាខណ្ឌទី១៧ ។

[38] សេចក្តីសម្រេចលើបណ្តឹងមុន, ដូចជើងទំព័រលេខ ១៤, កថាខណ្ឌ ២០។

*លម្អៀងជាក់ស្ដែង តាមរយៈការព្យាយាមប្ដឹងជិតចិត្តទៅក្រុមណាម្នាក់ដែលគេចង់ឱ្យរឿងក្ដីរបស់គេជំនុំជម្រះតាមគំនិតអ្នកផ្សេង ទំនងជាអាចសម្រេចលើសំណុំរឿងនោះតាមការចង់បាន [39]។*

## *ii. លក្ខណៈសមស្របនៃការប្រាស្រ័យទាក់ទង*

១៩- ដូចបានពិភាក្សាខាងលើពាក់ព័ន្ធនឹងការទទួលយកសំណើនេះ មេធាវីការពារក្ដីរបស់ នួន ជា ពុំបានផ្ដល់ភ័ស្តុតាងណាមួយ ដើម្បីបញ្ជាក់ថានៅក្នុងជំនួបប្រជុំនោះមានការពិភាក្សាអំពីអ្វីផ្សេងក្រៅពីបញ្ហារដ្ឋបាលឡើយ។ ការប្រាស្រ័យទាក់ទងមួយចំនួនរវាងអនុប្រធានអង្គជំនុំជម្រះ ព្រះរាជអាជ្ញា និង/ឬ អនុប្រធានការិយាល័យរដ្ឋបាលជាការចាំបាច់ និងសមស្របក្នុងបរិបទនៃតុលាការឧក្រិដ្ឋកម្មអន្តរជាតុបនីយកម្ម។ នៅតុលាការឧក្រិដ្ឋកម្មអន្តរជាតុបនីយកម្មដូច អ.វ.ត.ក សហព្រះរាជអាជ្ញាអន្តរជាតិ ដែលជាមន្ត្រីជាន់ខ្ពស់នៃ អ.ស.ប ពុំមានតួនាទីត្រឹមជាភាគីមួយនៃកិច្ចដំណើរការនីតិវិធីមួយមុខឡើយ។

២០- សហព្រះរាជអាជ្ញាអន្តរជាតិមានភារកិច្ចទទួលបន្ទុកកិច្ចការជាច្រើន ដូចជា ដែលក្នុងនោះមាន កិច្ចការរដ្ឋបាល, គ្រប់គ្រង, តាមដាន, ថវិកា, បុគ្គលិក, ទំនាក់ទំនងជាមួយមន្ត្រីជាន់ខ្ពស់ អ.ស.ប, ប្រមុខការទូត, ឥស្សរជន និងប្រទេសម្ចាស់ជំនួយ, ទំនាក់ទំនងជាមួយភ្នាក់ងារ អ.ស.ប នៅកម្ពុជា និងក្នុងតំបន់, រួមជាមួយសហព្រះរាជអាជ្ញាជាតិ ដើម្បីធានាថាការិយាល័យសហសហព្រះរាជអាជ្ញាមានធនធានចាំបាច់ មានការគាំទ្រភស្តុភារ និងរដ្ឋបាល ដើម្បីបំពេញតួនាទីរបស់ខ្លួនដោយអនុលោមតាមច្បាប់។ ក្នុងការបំពេញតួនាទីរបស់ខ្លួន សហព្រះរាជអាជ្ញាពុំចំណុះឱ្យស្ថាប័ននីតិបញ្ញត្តិ នីតិប្រតិបត្តិ ឬតុលាការនៃរដ្ឋាភិបាលកម្ពុជាឡើយ ហើយត្រូវបំពេញកិច្ចការដោយឯករាជ្យ និងមិនស្វែងរកការណែនាំពីសំណាក់រដ្ឋាភិបាល ឬប្រភពណាមួយឡើយ[40]។

២១- ទម្លាប់អនុវត្តដ៏ប្រសើរបំផុតរបស់តុលាការអន្តរជាតិ និងតុលាការអន្តរជាតុបនីយកម្ម និងតុលាការជំនុំជម្រះក្ដី បញ្ជាក់អំពីតម្រូវការឱ្យមានយន្តការ ដើម្បីគាំទ្រការគ្រប់គ្រងចាត់ចែងធនធានដ៏ប៉ិនប្រសប់ និងប្រកបដោយប្រសិទ្ធភាព និងការសម្របសម្រួលប្រកបដោយសីលវិធីខ្ពស់រវាង

[39] សំណុំរឿង *រដ្ឋអាជ្ញា ទល់នឹង Delalic et al.,* លេខសំណុំរឿង IT-96-21-A, សាលក្រម, ចុះថ្ងៃទី ២០ ខែ កុម្ភៈ ឆ្នាំ ២០០១, កថាខណ្ឌ ៧០៧ (លុបឯកសារយោង)។

[40] ច្បាប់ អ.វ.ត.ក, មាត្រា ១៩, កិច្ចព្រមព្រៀង មាត្រា ៦ (៣)។

ស្ថាប័នទទួលបន្ទុកការវិនិច្ឆ័យសេចក្តី ការចោទប្រកាន់ និងរដ្ឋបាល។ កិច្ចការសម្របសម្រួលនេះខុសពីបរិបទនៃ "កិច្ចដំណើរការនីតិវិធីនៅ អ.វ.ត.ក" ទាំងទស្សនទាន និងការអនុវត្តជាក់ស្តែង ត្រង់ថា វិធានផ្ទៃក្នុង "ធានាឲ្យមានការដាច់ពីគ្នា" រវាងការចោទប្រកាន់ និងការវិនិច្ឆ័យសេចក្តី[41]។ ដូចតាមការបញ្ជាក់របស់សហព្រះរាជអាជ្ញាអន្តរជាតិ Cayley គឺថាប្រសិនបើពុំមានជំនួបប្រជុំទាំងអស់នេះទេ "តុលាការអន្តរជាតិ និងតុលាការអន្តរជាតុបនីយកម្ម ក្នុងនោះមាន អ.វ.ត.ក ផង អាចជាប់គាំងពុំអាចបោះជំហានទៅមុខរួច"[42]។

២២- ជាឧទាហរណ៍ ចាប់ពីឆ្នាំ២០០១មក តុលាការព្រហ្មទណ្ឌអន្តរជាតិសម្រាប់អតីតប្រទេសយូហ្គោស្លាវី ("ICTY") បានបន្ថែមការិយាល័យរបស់ខ្លួន[43] ដែលមានគណៈកម្មការគ្រប់គ្រង[44] ដែលមានរចនាសម្ព័ន្ធ និងមុខងារស្រដៀងគ្នាទៅនឹងគណៈកម្មការរដ្ឋបាលតុលាការរបស់ អ.វ.ត.ក ("JAC") ដូចបានយោងនៅក្នុងពាក្យបណ្តឹងផងដែរ។ តុលាការ ICTY ក៏បន្ថែមឱ្យមានក្រុមប្រឹក្សាសម្របសម្រួលមួយ[45] ដែលមានសមាសភាពប្រធានមួយរូប រដ្ឋអាជ្ញាមួយរូប និងរដ្ឋបាលមួយរូប ដើម្បីធ្វើការសម្របសម្រួល "សកម្មភាពនានា" របស់អង្គភាពទាំងបី "ដើម្បីសម្រេចឱ្យបាននូវបេសកម្មរបស់តុលាការនោះ"[46]។ ការងាររបស់ក្រុមប្រឹក្សាសម្របសម្រួល ត្រូវពិចារណាឱ្យបានត្រឹមត្រូវទៅលើ "ការទទួលខុសត្រូវ និងឯករាជ្យភាព" របស់សមាជិកនៃក្រុមប្រឹក្សានេះ[47]។ រចនាសម្ព័ន្ធដូចគ្នាទាំងស្រុងនេះ ក៏មាននៅតុលាការព្រហ្មទណ្ឌអន្តរជាតិសម្រាប់ប្រទេសរ៉ាវ៉ាន់ដា ("ICTR") ផងដែរ[48]។ តុលាការព្រហ្មទណ្ឌអន្តរជាតិ ("ICC") ក៏អនុម័តឱ្យមានដំណើរការក្រុមប្រឹក្សាសម្របសម្រួលបែបនេះដែរ។ នៅតុលាការនីមួយៗក្នុងចំណោមតុលាការទាំងបីនេះ ភាគីការពារក្តីមិនមានតួនាទីអ្វីនៅក្នុងក្រុមប្រឹក្សាសម្របសម្រួលនេះឡើយ ហើយកំណត់ហេតុកិច្ចប្រជុំក៏មិនមែនជាឯកសារសាធារណៈដែរ។

---

[41] វិធាន ២១(១)(ក)។

[42] Julia Wallace, មេធាវីការពារក្តីនៅសាលាក្តីខ្មែរក្រហមចោទប្រកាន់ថាមានជំនួបប្រជុំតែមួយភាគី, សារព័ត៌មាន Cambodia Daily, ចុះថ្ងៃទី ៧ ខែ វិច្ឆិកា ឆ្នាំ ២០១១, ទំព័រ ២។

[43] វិធានស្តីពីនីតិវិធី និងភស្តុតាង របស់ ICTY វិធាន ២៣។

[44] វិធានស្តីពីនីតិវិធី និងភស្តុតាង របស់ ICTY វិធាន ២៣ *ស្ទួនទីពីរ*។

[45] វិធានស្តីពីនីតិវិធី និងភស្តុតាង របស់ ICTY វិធាន ២៣ *ស្ទួន*។

[46] *ដូចលេខយោងជើងទំព័រខាងលើ*។

[47] *ដូចលេខយោងជើងទំព័រខាងលើ*។

[48] វិធានស្តីពីនីតិវិធី និងភស្តុតាង របស់ ICTR វិធាន ២៣ វិធាន២៣ *ស្ទួន* និងវិធាន ២៣ *ស្ទួនពីរ*។

២៣- លក្ខណៈកូនកាត់ និងវិសាលភាពដែលមានលក្ខណៈប្រសើរសមស្របរបស់ អ.វ.ត.ក ជាពិសេសមុខងាររដ្ឋបាលដែលមាននៅគ្រប់ទិសទីនៅក្នុងតុលាការនេះ មិនអាចធានាថាគ្រប់រចនាសម្ព័ន្ធផ្លូវការទាំងអស់ដែលមាននៅតាមតុលាការពិសេសនានា និងនៅតុលាការព្រហ្មទណ្ឌអន្តរជាតិមានអាត្ថិភាពឡើយ[49]។ ប៉ុន្តែ កត្តានេះមិនដកនូវតម្រូវការដ៏ចាំបាច់ សម្រាប់កិច្ចសម្របសម្រួលរវាង លោកស្រីចៅក្រម Cartwright ក្នុងនាមលោកស្រីជាអនុប្រធាននៃកិច្ចប្រជុំពេញអង្គ និងជាមន្ត្រីតុលាការអន្តរជាតិជាន់ខ្ពស់ ដែលមានបទពិសោធន៍ជ្រៅជ្រះ ជាមួយនឹងលោកសហព្រះរាជអាជ្ញាអន្តរជាតិ និង/ឬ លោកអនុប្រធានការិយាល័យរដ្ឋបាលនោះទេ ដែលគាត់ក៏មានការទទួលខុសត្រូវដ៏សំខាន់ៗជាក់លាក់ចំពោះបុគ្គលិកអន្តរជាតិ ដោយអនុលោមតាមមាត្រា ៣១ ថ្មី នៃច្បាប់ អ.វ.ត.ក។ កិច្ចសម្របសម្រួលបែបនេះ មិនមានផលអាក្រក់ ឬខុសច្បាប់ឡើយ។ ផ្ទុយទៅវិញ រាល់បញ្ហាណាមួយនៅក្នុងកិច្ចពិភាក្សា ក្នុងអំឡុងពេលនៃកិច្ចប្រជុំរដ្ឋបាលក្រៅផ្លូវការទាំងនេះ ពាក់ព័ន្ធតែទៅនឹងបញ្ហាប្រតិបត្តិមួយចំនួនរបស់តុលាការដែលមានលក្ខណៈអន្តរជាតិ ដែលមិនពាក់ព័ន្ធទៅនឹង "កិច្ចដំណើរការនីតិវិធីរបស់ អ.វ.ត.ក" ឡើយ ហើយក៏មិនប៉ះពាល់ដល់ជនជាប់ចោទជាក់លាក់ណាមួយនោះដែរ។ បន្ថែមលើនេះ មិនមានចំណុចណាមួយនៅក្នុងវិធានផ្ទៃក្នុង ដែលហាមឃាត់មិនឱ្យមានកិច្ចប្រជុំរដ្ឋបាលនោះទេ ហើយក៏មិនមានចំណុចណាមួយនៅក្នុងវិធានផ្ទៃក្នុងដែលចែងថា គណៈកម្មការរដ្ឋបាលតុលាការ គឺជា "យន្តការតែមួយគត់"[50] សម្រាប់កិច្ចប្រជុំរដ្ឋបាល ដូចដែលក្រុមមេធាវីការពារក្តីបានអះអាងនោះដែរ។

២៤- មិនត្រឹមតែប្រព័ន្ធតុលាការអន្តរជាតិនោះទេ សូម្បីតែប្រព័ន្ធច្បាប់ស៊ីវិលក៏តម្រូវឱ្យមានការប្រាស្រ័យទាក់ទងគ្នាជាក់លាក់មួយចំនួនរវាងចៅក្រម និងព្រះរាជអាជ្ញា ឬរដ្ឋអាជ្ញាដែរ។ សហព្រះរាជអាជ្ញាមាន "ឋានៈពិសេសមួយ ដែលជាមន្ត្រីតុលាការ ដែលផ្តល់ឱ្យតាមរយៈច្បាប់កម្ពុជា"[51]។ ហេតុដូច្នេះ សហព្រះរាជអាជ្ញាមានសិទ្ធិចូលរួម និងបោះឆ្នោតលើវិធាននានា ដែលពាក់ព័ន្ធទៅនឹង

[49] អង្គជំនុំជម្រះសាលាដំបូងធ្លាប់បានកត់សម្គាល់រួចហើយថា៖ "អ.វ.ត.ក មានលក្ខណៈជាច្រើន ដែលខុសពីតុលាការ និងសាលាក្តីដែលមានលក្ខណៈអន្តរជាតិដទៃទៀត"។ ឯកសារ **E5/3** *សេចក្តីសម្រេចលើពាក្យបណ្តឹងជំទាស់របស់ លោក អៀង សារី ចំពោះចៅក្រម និល ណុន និងសំណើសុំពាក់ព័ន្ធនានា* ចុះថ្ងៃទី ២៨ ខែ មករា ឆ្នាំ ២០១១ កថាខណ្ឌ ១៤។

[50] **E137/2** ពាក្យបណ្តឹង *ដូចខាងលើ* កំណត់សម្គាល់លេខ ៦ ត្រង់កថាខណ្ឌ ១០។

[51] វិធាន ១៨(៣)(ក) នៃវិធានផ្ទៃក្នុង។

បញ្ហារដ្ឋបាល[52]។ នេះគឺជាការឆ្លុះបញ្ចាំងមួយនៃទំនៀមទម្លាប់ច្បាប់ស៊ីវិល ដែលក្នុងប្រព័ន្ធច្បាប់នេះ ព្រះរាជអាជ្ញា គឺជាសមាជិករបស់តុលាការ។ ជាឧទាហរណ៍ ប្រព័ន្ធច្បាប់បារាំង *ផ្តល់អាណត្តិ* ជាវិជ្ជមានដល់ព្រះរាជអាជ្ញា ដើម្បីប្រាស្រ័យទាក់ទងគ្នាជាប្រចាំជាមួយនឹងចៅក្រម ចំពោះបញ្ហានានាពាក់ព័ន្ធនឹងរដ្ឋបាលល្អរបស់តុលាការ ឱ្យបានទូលំទូលាយ ដូចទៅនឹងប្រសិទ្ធភាពសម្រាប់ការផ្តន្ទាទោសព្រហ្មទណ្ឌ[53] ការទទួលខុសត្រូវព្រហ្មទណ្ឌចំពោះអនីតិជន[54] និងចំនួនម៉ោងធ្វើការរបស់តុលាការ[55]។ ការប្រាស្រ័យទាក់ទងគ្នាបែបនេះ ដែលជាបញ្ហាបច្ចេកទេសរដ្ឋបាល មិនត្រូវបូករួមអ្នកតំណាងរបស់ភាគីការពារក្តីឡើយ។ ចំណុចនេះក៏ស្របគ្នាទៅនឹងគោលការណ៍លេខ ២០ នៃ *សេចក្តីណែនាំអន្តរជាតិស្តីពីតួនាទីរបស់រដ្ឋអាជ្ញា* ផងដែរ៖

> *ដើម្បីធានាដល់ភាពត្រឹមត្រូវ និងប្រសិទ្ធភាពនៃការចោទប្រកាន់ រដ្ឋអាជ្ញាត្រូវខិតខំប្រឹងប្រែងសហការជាមួយនគរបាល តុលាការ អ្នកច្បាប់ អ្នកការពារក្តី និងទីភ្នាក់ងារ ឬស្ថាប័នរដ្ឋាភិបាលដទៃទៀត*[56] ។

*iii. សេចក្តីសន្និដ្ឋាន*

២៥- ក្រុមមេធាវីការពារក្តីរបស់ នួន ជា មិនបង្ហាញភស្តុតាងឱ្យបានគ្រប់គ្រាន់ដើម្បីដាក់បន្ទុក ក្នុងការបង្ហាញថា បុគ្គលប្រកបដោយលក្ខណៈសត្យានុម័ត ប្រកបដោយហេតុផល និងប្រកបដោយ

---

[52] វិធាន ១៨(៣)(ក) នៃវិធានផ្ទៃក្នុង។

[53] "សារាចរពាក់ព័ន្ធនឹងប្រសិទ្ធភាពនៃការទទួលខុសត្រូវព្រហ្មទណ្ឌ CRIM 2002-08 E3/10-04-2002 NOR : JUSD0230067C ការអនុវត្តទោស-គោលនយោបាយព្រហ្មទណ្ឌ" ព្រឹត្តិបត្រផ្លូវការក្រសួងយុត្តិធម៌ លេខ ៨៦ (០១ មេសា-៣០ មិថុនា ២០០២) សារាចរស្តីពីការគ្រប់គ្រងសំណុំរឿងព្រហ្មទណ្ឌ និងការលើកលែងទោស កម្រងសារាចរចេញផ្សាយពីថ្ងៃទី ០១ ខែ មេសា ដល់ថ្ងៃទី ៣០ ខែ មិថុនា ឆ្នាំ ២០០២។

[54] "គោលនយោបាយព្រហ្មទណ្ឌពាក់ព័ន្ធនឹងបទល្មើសលើអនីតិជន, CRIM 2002-17 E1/13-12-2002 NOR : JUSD0230200C, បទល្មើស-អនីតិជន-គោលនយោបាយព្រហ្មទណ្ឌ" ព្រឹត្តិប័ត្រផ្លូវការក្រសួងយុត្តិធម៌ លេខ ៨៨ (០១ តុលា-៣១ ធ្នូ ២០០២) សារាចរស្តីពីការគ្រប់គ្រងសំណុំរឿងព្រហ្មទណ្ឌ និងការលើកលែងទោស កម្រងសារាចរចេញផ្សាយពីថ្ងៃទី ០១ ខែ តុលា ដល់ថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ២០០២។

[55] «Circulaire ARTT pour les magistrats des juridictions, de l'ENM et de l'ENG, SJ 2001-11 DSJ/12-12- 2001 NOR : JUSB0110566C, ARTT - Temps de travail » ព្រឹត្តិបត្រផ្លូវការក្រសួងយុត្តិធម៌ លេខ ៨៥ (០១ មករា-៣១ មីនា ២០០២) សារាចរស្តីពីការគ្រប់គ្រងសេវាតុលាការ កម្រងសារាចរចេញផ្សាយពីថ្ងៃទី ០១ ខែ មករា ដល់ថ្ងៃទី ៣១ ខែ មីនា ឆ្នាំ ២០០២។

[56] ត្រូវបានអនុម័តដោយសមាជអង្គការសហប្រជាជាតិលើកទី ៨ ស្តីពីការទប់ស្កាត់បទល្មើស និងការប្រព្រឹត្តមកលើជនល្មើស ទីក្រុងហាវ៉ាណា ប្រទេសគុយបា ពីថ្ងៃទី ២៧ ខែ សីហា ដល់ថ្ងៃទី ៧ ខែ កញ្ញា ឆ្នាំ ១៩៩០។

ចំណេះដឹង អាចចាប់បានប្រកបដោយហេតុផលថា មានភាពលម្អៀងចំពោះលោកស្រីចៅក្រម Cartwright នៅក្នុងស្ថានភាពនេះ។ ដូចបានពន្យល់ខាងលើរួចមកហើយ ទាក់ទងទៅនឹងភាពអាចទទួលយកបាននៃសំណើសុំនេះ ក្រុមមេធាវីការពារក្តី នួន ជា មិនបានបង្ហាញភស្តុតាង ដើម្បីបញ្ជាក់អំពីភាពលម្អៀង និយាយតែភស្តុតាងដាក់បន្ទុកតែមួយប៉ុណ្ណោះ ជាពិសេស ចំពោះការអនុវត្តទូទៅ និងដែលអាចទទួលយកបាននៃកិច្ចប្រជុំផ្ទៃក្នុងរដ្ឋបាល ទាំងនៅតុលាការអន្តរជាតិ និងតុលាការស៊ីវិលនានា[57]។

## III. សំណើសុំឱ្យធ្វើការស៊ើបអង្កេត គួរត្រូវបានបដិសេធចោល

២៦- ក្រុមមេធាវីការពារក្តីរបស់ អៀង សារី ស្នើសុំឱ្យអង្គជំនុំជម្រះផ្តួចផ្តើមការស៊ើបអង្កេតដោយអនុលោមតាមវិធាន ៣៥ នៃវិធានផ្ទៃក្នុង ផ្អែកភាគច្រើនទៅលើការចោទប្រកាន់ដូចគ្នាទៅនឹងក្រុមមេធាវីការពារក្តីរបស់ នួន ជា ដែរ និងបានលើកឡើងថាតើការស៊ើបអង្កេតគួរត្រូវបានធ្វើឡើងដោយរបៀបណានោះ។

២៧- ដើម្បីបំពេញបន្ទុករបស់ខ្លួនស្ថិតនៅក្រោមវិធាន ៣៥ នៃវិធានផ្ទៃក្នុង ក្រុមមេធាវីការពារក្តីរបស់ អៀង សារី ត្រូវតែបង្ហាញ "ហេតុផលឱ្យជឿជាក់បាន" ថា បុគ្គលម្នាក់ "បានជ្រៀតជ្រែកដោយដឹង និងដោយចេតនាចូលក្នុងកិច្ចការរដ្ឋបាលរបស់តុលាការ"។ ដើម្បីឱ្យដឹងថា បទដ្ឋានស្តីពី"ហេតុផលឱ្យជឿជាក់បាន" ត្រូវបានបំពេញ អង្គជំនុំជម្រះត្រូវតែរកឱ្យឃើញថា "មានភាពលម្អៀង ឬមូលហេតុជាក់លាក់ដែលជាមូលដ្ឋាននៃជំនឿរបស់ខ្លួន"[58]។ មូលហេតុជាក់លាក់ មិនមែនការចោទប្រកាន់ស្មានៗទេ ត្រូវតែគាំទ្រដល់ធាតុផ្សំដែលបានចោទប្រកាន់ ឬ*អំពើពិរុទ្ធ* មានន័យថា "ការជ្រៀតជ្រែកចូលក្នុងកិច្ចការរដ្ឋបាលរបស់តុលាការ" និងធាតុផ្សំចេតនាដែលបានចោទប្រកាន់ ឬ

---

[57] ការមើលស្រាលបន្ថែមទៀតដល់ភាពសមហេតុសមផលនៃសំណើរបស់ នួន ជា សុំប្តឹងជំទាស់ ដោយសារថា ក្រុមមេធាវីការពារក្តីរបស់ អៀង សារី ដែលជាសហជនជាប់ចោទរបស់ នួន ជា ក៏សម្អាងទៅលើអង្គហេតុតែមួយ ប៉ុន្តែ ខំប្រឹងពន្យល់ថា សំណើរបស់ពួកគេថា "មិនមែនជាបណ្តឹងសុំជំទាស់ឡើយ"។ សំណើលេខ E137/3 លេខយោងទី ១០ *ខាងលើ* ត្រង់ទំព័រទី ១។

[58] ឯកសារលេខ **D314/1/12** *សាលដីកាលើកទីពីរលើបណ្តឹងឧទ្ធរណ៍របស់លោក នួន ជា និងលោក អៀង សារី ប្រឆាំងនឹងដីកាសម្រេចរបស់ ក.ស.ច.ស លើសំណើសុំឱ្យកោះហៅសាក្សី ចុះថ្ងៃទី ៩ ខែ កញ្ញា ឆ្នាំ ២០១០ កថាខណ្ឌ ៣៧ (សាលដីកាលើកទីពីរ")*។

*ចេតនាឧក្រិដ្ឋ* មានន័យថា "ដោយចេតនា និងដោយការដឹង"។ នៅក្នុងវិធាន ៣៥ នៃវិធានផ្ទៃក្នុង អត្ថន័យនៃពាក្យថា "រដ្ឋបាលតុលាការ" ពាក់ព័ន្ធតែទៅនឹងបញ្ហាដែល "ជាប់ទាក់ទងយ៉ាងជិតជិត ទៅនឹងការប្រព្រឹត្តិទៅនៃដំណើរការនីតិវិធី នៅចំពោះមុខតុលាការនេះ" តែប៉ុណ្ណោះ[59]។

២៨- ក្រុមមេធាវីការពារក្ដីរបស់ អៀង សារី ខកខានទាំងស្រុងក្នុងការបង្ហាញឲ្យឃើញមូលដ្ឋានជាក់លាក់ ចំពោះការចោទប្រកាន់របស់ខ្លួន។ ការខកខានរបស់ពួកគេ មានពីរចំនុច៖ ទីមួយ ពួកគេខកខានមិន បានបង្ហាញឲ្យឃើញនូវមូលដ្ឋានជាក់លាក់ ដើម្បីចង្អុលបង្ហាញឲ្យឃើញនូវ *អំពើពិរុទ្ធ* ដែលថា កិច្ច ប្រជុំផ្ទៃករដ្ឋបាល បង្កទៅជាការជ្រៀតជ្រែកក្នុងកិច្ចការរដ្ឋបាលរបស់តុលាការ ពាក់ព័ន្ធទៅនឹង អៀង សារី ក្នុងសំណុំរឿង ០០២។ ក្រុមមេធាវីការពារក្ដីរបស់ អៀង សារី មិនបានបង្ហាញភ័ស្តុតាង ឲ្យលើសពីក្រុមមេធាវីការពារក្ដីរបស់ នួន ជា ដែរ ហើយភាគច្រើនបង្ហាញថា មានកិច្ចប្រជុំផ្ទៃក រដ្ឋបាល ដែលអាចទទួលយកបានដោយឥតខ្ចោះ នៅក្នុងបរិបទច្បាប់អន្តរជាតិ និងច្បាប់ស៊ីវិល[60]។ តាមពិតទៅ លោក Karnavas ដែលជាសហមេធាវីអន្តរជាតិនៃក្រុមមេធាវីការពារក្ដីរបស់ អៀង សារី បានលើកជូនអង្គជំនុំជម្រះថា ទាក់ទងទៅនឹងកិច្ចប្រជុំទាំងនេះ "យើងខ្ញុំមិនមានការលើកឡើង ថា មានបញ្ហាមិនសមស្របបានកើតឡើង ..."។

២៩- ទីពីរ ក្រុមមេធាវីការពារក្ដីរបស់ អៀង សារី *មិនបាន*លើកឡើងនូវទឡ្ហីករណ៍ដែលថា ការជ្រៀត ជ្រែកចូលក្នុងកិច្ចការរដ្ឋបាលរបស់តុលាការ ត្រូវបានធ្វើឡើងដោយមាន*ចេតនាឧក្រិដ្ឋ*នោះទេ[61] មាន ន័យថា វាត្រូវបានធ្វើឡើងដោយដឹងថា ការពិភាក្សាអំពីបញ្ហារដ្ឋបាល គឺជាការជ្រៀតជ្រែកចូលក្នុង កិច្ចការរដ្ឋបាលរបស់តុលាការ និងទោះជាយ៉ាងណាក៏ដោយ ដឹងថាមានការជ្រែតចូលដោយចេតនា

[59] រដ្ឋអាជ្ញា តទល់នឹង *Milošević* សំណុំរឿងលេខ IT-02-54-Misc5 និង IT-02-54-Misc6, *សេចក្ដីសម្រេចអំពីគំនិត ផ្ដួចផ្ដើមនៃការស៊ើបអង្កេតទៅលើការប្រមាថតុលាការ ចុះថ្ងៃទី ១៨ ខែ កក្កដា ឆ្នាំ ២០១១ កថាខណ្ឌ ១១*។ អ.វ.ត.ក បាន កត់សម្គាល់នូវភាពប្រហាក់ប្រហែលគ្នានៃវិធាន ៣៥ ទៅនឹងវិធាន ៧៧ នៃវិធានស្ដីពីនីតិវិធី និងភ័ស្តុតាងនៃតុលាការ ICTY និង បានរកឃើញថាការបកស្រាយវិធាន ៧៧ នេះគឺជាសេចក្ដីណែនាំមួយ។ សាលដីកាលើកទីពីរលេខ **D314/1/12** លេខយោង ៥៨ *ខាងលើ* ត្រង់កថាខណ្ឌ ៣១ និងកថាខណ្ឌ ៣២។

[60] ប្រតិចារឹក ចុះថ្ងៃទី ២១ ខែ វិច្ឆិកា ឆ្នាំ ២០១១ ទំព័រ ១៣ បន្ទាត់ទី ៩។

[61] មេធាវីការពារក្ដីបានរៀបរាប់អំពីបទដ្ឋាន *ចេតនាឧក្រិដ្ឋ* (*mens rea*) តែម្ដងប៉ុណ្ណោះ ដោយប្រើប្រាស់ពាក្យពេចន៍ ដែលមាន នៅក្នុងវិធាន ៣៥ នៃវិធានផ្ទៃក្នុង។ សូមមើលឯកសារ **E137/3** *ដូចខាងលើ* កំណត់សម្គាល់លេខ ១០ ត្រង់កថាខណ្ឌ ១។

[62]។ ជាលទ្ធផល ក្រុមមេធាវីការពារក្តីរបស់ អៀង សារី មិនបានបំពេញបន្ទុករបស់ខ្លួនដើម្បីបង្ហាញថា មានមូលហេតុជាក់លាក់ចំពោះសំណើរបស់ខ្លួននោះទេ។ ដូច្នេះ សំណើសុំនេះត្រូវបដិសេធចោល។

## IV. ដំណោះស្រាយ

៣០- ដោយយោងទៅលើសម្អាងហេតុទាំងអស់នេះ សហព្រះរាជអាជ្ញាសូមស្នើឲ្យអង្គជំនុំជម្រះសាលាដំបូងបដិសេធពាក្យសុំរបស់ នួន ជា និងច្រានចោលសំណើរបស់ អៀង សារី ដោយសារមិនអាចទទួលយកបាន គ្មានសម្អាងហេតុ ពន្យារនីតិវិធី និង/ឬ មិនមែនជាផលប្រយោជន៍យុត្តិធម៌។

| កាលបរិច្ឆេទ | ឈ្មោះ | ទីកន្លែង | ហត្ថលេខា |
|---|---|---|---|
| ថ្ងៃទី១ ខែធ្នូ ឆ្នាំ២០១១ | **លោកស្រី ជា លាង**<br>សហព្រះរាជអាជ្ញា | ភ្នំពេញ | [signature] |
| | **លោក** William SMITH<br>សហព្រះរាជអាជ្ញារង | | [signature] |

[62] ជាទូទៅ សូមមើលសំណុំរឿង *រដ្ឋអាជ្ញា តទល់នឹង Šešelj* ឯកសារ Case IT-03-67-R.77.4 *ឯកសារសាធារណៈដែលត្រូវបានសម្រួល "សេចក្តីសម្រេចលើការខកខាតមិនបានដកចេញនូវព័ត៌មានសម្ងាត់ពីបណ្តាញអ៊ីធឺណែតសាធារណៈ និងដីកាសម្រេចជំនួសឲ្យការចោទប្រកាន់" ដែលបានចេញ ចុះថ្ងៃទី០៩ ខែឧសភា ឆ្នាំ២០១១* ឯកសារចុះថ្ងៃទី ២៤ ខែ ឧសភា ឆ្នាំ ២០១១ កថាខណ្ឌ ២៧។ *សំណុំរឿង រដ្ឋអាជ្ញា តទល់នឹង Milošvić* ឯកសារ Case IT-02-54-A-R77.4 *សេចក្តីសម្រេចលើបណ្តឹងឧទ្ធរណ៍ចាត់របៀប លើនីតិវិធីពាក់ព័ន្ធនឹងការប្រមាថតុលាការរបស់ Kosta Bulatović* ចុះថ្ងៃទី ២៩ ខែ សីហា ឆ្នាំ ២០០៥ កថាខណ្ឌ ៤០ ដល់ ៤៣។